# សេចក្តីជូនដំណឹង

## ស្តីពី

## ការបែងចែកភាគលាភ

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ មេត្តាជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេច នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៦ របស់ធនាគារ អេស៊ីលីដា នាថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៦ លិខិតលេខ ១៥៩៩/២៦ ន.ម.ក. ចុះថ្ងៃព្រហស្បតិ៍ ១២កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៦ របស់និយ័តករមូលបត្រកម្ពុជា ស្តីពីការបែងចែកភាគលាភ សម្រាប់ឆ្នាំ២០២៥ និងលិខិតលេខ ធ១៧-០២៦-១២៤២ ឆ.ត ចុះថ្ងៃសុក្រ ៥រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៦ របស់ធនាគារជាតិ នៃ កម្ពុជា ធនាគារ អេស៊ីលីដា សម្រេចបែងចែកភាគលាភសម្រាប់ប្រាក់ចំណេញឆ្នាំ២០២៥ ជូនភាគហ៊ុនិក ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | ប្រភេទភាគលាភដែលត្រូវបែងចែក | **: សាច់ប្រាក់** |
| ២. | រយៈពេល នៃភាគលាភ | **: ប្រចាំឆ្នាំ** |
| ៣. | អនុបាត នៃការបែងចែកភាគលាភ | **: ២៩.៩៩%** |
| ៤. | ភាគលាភសរុបដែលត្រូវបែងចែក | **: ២៤០,៤០៥,៤៧៥,៥៤៥ រៀល** |
| ៥. | ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | **: ៥៥៥ រៀល** |
| ៦. | កាលបរិច្ឆេទអិចឌីវីដឺនដ៍ | **: ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៦** |
| ៧. | កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលភាគលាភ (កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ) | **: ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦** |
| ៨. | កាលបរិច្ឆេទទូទាត់ភាគលាភ | **: ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៦** |

**<u>បញ្ជាក់៖</u>**

- ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភដូចការកំណត់ខាងលើ គឺជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក (Record Date) នៅ**ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦**។
- ភាគហ៊ុនិកដែល**លក់**មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៦ គឺនៅតែមានសិទ្ធិ**ទទួលបានភាគលាភនេះដដែល។
- ភាគហ៊ុនិកដែល**ទិញ**មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៦ គឺមិនមានសិទ្ធិ**ទទួលបានភាគលាភនេះទេ។
- ការទូទាត់ភាគលាភនឹងចាប់ផ្តើមពី**ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៦ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៦** នៅរៀងរាល់ថ្ងៃធ្វើការ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកផ្នែកប្រតិបត្តិការបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ (**ភ្នាក់ងារ RTP**) ដូចខាងក្រោម៖

- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ**
  - ទូរស័ព្ទ: (៨៥៥) ៧០ ៥០០ ៣៧៧
  - អ៊ីម៉ែល: samreth.vannybopharath@acledabank.com.kh
- **កញ្ញា ចាន់ ទេពកញ្ញា**
  - ទូរស័ព្ទ: (៨៥៥) ១៦ ២៩៥ ៤៣២
  - អ៊ីម៉ែល: op.rtp@acledabank.com.kh
- **លោក កែន រិទ្ធពុទ្ធា**
  - ទូរស័ព្ទ: (៨៥៥) ១៥ ៨០០ ៦៦៣
  - អ៊ីម៉ែល: ken.rithputhea@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃសុក្រ ៥រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៦

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**